ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៩២ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ៤៣ រូប ៤៩៦៦

២២-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៩៣ ស្ដីពីការផ្ទេរមុខតំណែងលោក **ថុល គីមហ៊ឹង** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ឱ្យមកបំរើការងារនៅទីស្ដីការក្រសួងយុត្តិធម៌ ដោយរក្សាទុកនូវឋានៈ និង បៀវត្សដដែល ៤៩៦៨

២៨-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៩៨ ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ៤៩៦៩

២៨-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៥៩៩ ស្ដីពី ការតែងតាំងឯកឧត្តម **សៀង ផេង** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ៤៩៧០

២៨-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៦០០ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ការពារជាតិ តាមលំដាប់ថ្នាក់ ចំពោះ គ្រួសារយុទ្ធជន ចំនួន ២៧ រូប ៤៩៧១

២៨-៦-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៦១២/៦០១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំនួន ១៣ រូប ៤៩៧២

II-រាជរដ្ឋាភិបាល

អនុក្រឹត្យ

២៨-៦-២០១២ -អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្ដីពី ការកែសម្រួលអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ៤៩៧៣

២៨-៦-២០១២ -អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្ដីពី ការឈប់ទទួលស្គាល់សាកលវិទ្យាល័យស៊ីធី ៤៩៨១

២៩-៦-២០១២ -អនុក្រឹត្យលេខ ៩៩ អនក្រ.បក ស្ដីពី ការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ៤៩៨៣

២៩-៦-២០១២ -អនុក្រឹត្យលេខ ៧៦០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៤៩៨៥

២៩-៦-២០១២ -អនុក្រឹត្យលេខ ៧៦១ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៤៩៩០

២៩-៦-២០១២ -អនុក្រឹត្យលេខ ៧៦២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤៩៩៣
២៩-៦-២០១២ -អនុក្រឹត្យលេខ ៧៦៣ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥០០០
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០០១
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០១៤
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០១៦
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៧ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥០៤៦
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥០៤៧
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៦៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០៤៨
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៧០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៤៩
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៧១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥០៥០
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៧២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥០៥២
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៧៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥០៥៣
០២-៧-២០១២ -អនុក្រឹត្យលេខ ៧៧៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥០៥៤

III~ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៦៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេអិល ស៊ីវើលឌ៍ គ្រេឌីង អ៊ីន** ៥០៦០
១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បាន សុខជាតិ** ៥០៦២
១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វ.អាយ.ឌី.ជី (ខេមបូឌា)** ៥០៦៤
១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៧០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីអេចខេ ប៊ីហ្សនេស គ្រុប** ៥០៦៦
១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៧១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម៉ារ៉ាយ ខនសាល់ធីង** ៥០៦៨
១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៧៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វជីតី (ខេមបូឌា) លីមីធីត** ៥០៧០

១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៧៩ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកលក្ខន្តិកៈថ្មី របស់ក្រុមហ៊ុន **ភ្នំពេញ ស្ទូឌ្យោ** ៥០៧២

១៧-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៨៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីមើស គ្រេឌីត** ៥០៧៤

១៨-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ អេឌើអេសិន អេតស្តើត** ៥០៧៦

១៨-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៩២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីណាហ្គុហ្វ អន្តរ ធ្វើហ្សើម យ៉ាញ ស្តុត ខមភេនី** ៥០៧៨

១៨-៣-២០១១ -លិខិតបញ្ជាក់លេខ ១៤៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចន្ទី ឡូង អ៊ីម អិច** ៥០៨០

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៤៣ រូប ដែលមានគុណបំណាច់ក្នុងការចូលរួម
ចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

នូវ

ក/ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- លោកស្រី ឡុង ផល្លី
២- លោក ហេង ចាន់សារិន
៣- លោក លូ រដ្ឋី
៤- លោក ទូច ខាន់ជា
៥- លោក អ៊ូ ភូងមរកត

ខ/ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ព្រាប សំអាត
២- លោក អ៊ុំសន សុភារៈ
៣- លោកស្រី ប៉ាន់ សូនី
៤- លោក ហេង សុវណ្ណនា
៥- លោក ប៊ុន ណារិទ្ធ
៦- លោក ប៉ាន់ ដារា
៧- លោក មុត សារីដា
៨- លោកស្រី ហោ ផាន
៩- លោកស្រី ធុច ថារី
១០- លោក ម៉ា សុផល
១១- លោកស្រី ភា ចន្ថា
១២- លោកស្រី ជួប ហ្សឺឌី

គ/ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោកស្រី គង់ ដាណេត
៨- លោកស្រី គីម ផាផន

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

២- លោកស្រី ហេង ច័ន្ទត្រឹះស្នា
៣- លោកស្រី ហេង ច័ន្ទវ័ត្តថា
៤- លោក នួន ណន
៥- លោកស្រី នួន ថាវី
៦- លោក ហែម សាវ៉ាត
៧- លោក ង៉ាន សុភី
៩- លោកស្រី អ៊ឹម សុធី
១០- លោកស្រី មួង គីមយុន
១១- លោក កែវ សុវណ្ណារ៉ា
១២- លោកស្រី សាខន លីនដា
១៣- លោកស្រី នួន ពៅ
១៤- លោក ជាវ ចាន់ថន

ឃ/ គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក អ៊ិត ហោ
២- លោក ទូន ប៉ូលីន
៣- លោកស្រី អ៊ូសន សុកញ្ញា
៤- លោកស្រី អាត ច័ន្ទសុវណ្ណពិសី
៥- លោកស្រី យី គន្ធី
៦- លោកស្រី អ៊ូសន សូដាណា
៧- លោកស្រី ស៊ូ លីណា
៨- លោកស្រី កែវ សុភាព
៩- លោក អ៊ូសន សុភារ៉ា
១០- លោកស្រី អ៊ូសន សូដានី
១១- លោកស្រី សាត គីមហេង
១២- លោក ហេង សុផាណា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ទល.១២០៦.៥៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១២

លេខៈ ៥៦៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៩៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រតនត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រមលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានផ្ទេរមុខតំណែងលោក **ថុល គឹមហ៊ើង** ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តព្រះវិហារ ឲ្យមកបំពេញការងារនៅទីស្តីការក្រសួងយុត្តិធម៌ ដោយរក្សាទុកនូវឋានៈ និងថ្នាក់ដដែល ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៣: ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣១៧.១២០៦.៥៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២

លេខៈ ៤៦៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០១២
អនុរលេខាធិការស្តីទីរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៩៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

ក- ថ្នាក់ឧត្តមសេនីយ៍ឯក ជូនលោកស្រីឧត្តមសេនីយ៍ទោ **ថន សុវណ្ណច័ន្ទខេម៉ា** អត្តលេខ ៥៤៥៦៣ ។

ខ- ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **ហៀ រិទ្ធី** អត្តលេខ ៦៧០១០ ។

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣៩៩.១២០៦.៥០៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
... សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៥៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **សៀង ផេន** ជាទីប្រឹក្សាក្រសួងមហាផ្ទៃ មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៥៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០១២
អគ្គលេខាធិការគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល
ស៊ុយ សុខា

៣១៧. ១២០៦. ២០៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៦០០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

គ្រួសារយុទ្ធជន ចំនួន ២៧រូប ដែលមានប្ដី និងកូនបានពលីជីវិត
នៅក្នុងសមរភូមិប្រយុទ្ធការពារព្រំដែនកម្ពុជា-ថៃ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយសការពារជាតិ ថ្នាក់ មាស :

១-	លោកស្រី	ណុក ផៃ	១២-	លោកស្រី	អ៊ុំម ខា
២-	លោកស្រី	ឌឹប ហុយ	១៣-	លោកស្រី	គុប ម៉ុនធឿន
៣-	លោកស្រី	ស៊ុន ស៊ុំ	១៤-	លោកស្រី	ចាន់ សុខន
៤-	លោកស្រី	ខិញ សម្បត្តិ	១៥-	លោកស្រី	ស៊ុន ចាន់លី
៥-	លោកស្រី	ម៉ុច ខុម	១៦-	អ្នកស្រី	សេង គា
៦-	លោកស្រី	គី លី	១៧-	អ្នកស្រី	ជេម ឆេន
៧-	លោកស្រី	ឡឿង គី	១៨-	លោកស្រី	ម៉ាស់ សឿន
៨-	លោកស្រី	ឆាច ម៉ាន់	១៩-	លោកស្រី	ហ៊ុម វណ្ណៈ
៩-	លោកស្រី	ចាន់ ម៉ៅ	២០-	លោក	រស់ យ៉ែម
១០-	លោកស្រី	ឃួត សាវឿប	២១-	លោកស្រី	ចេង ស្រីចាន់
១១-	លោកស្រី	ប្រាង ជឿន			

ខ-គ្រឿងឥស្សរិយយសការពារជាតិ ថ្នាក់ ប្រាក់ :

១-	លោកស្រី	បៀ សាន់	៤-	លោកស្រី	នុត សាលើម
២-	លោកស្រី	គួយ សុខា	៥-	លោកស្រី	សាយ សុវណ្ណ
៣-	លោកស្រី	អឿម យឿម	៦-	លោកស្រី	សាន យ៉ែម

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ចាស.១២០៦-៦០៦

លេខៈ ៥៧២ ច.ល
ដើម្បីចម្លងចែកភ្ជាប់
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១២
[illegible]
សុខា

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៦១២/៦០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំនួន ១៣រូប
មានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ លើការងាររៀបចំការបោះឆ្នោត

នូវ

ក- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោក មុំ សុទ្ធ
២- លោក ផាន់ ចណ្ណសិទ្ធិ
៣- លោក ហួត ផុន

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១- លោក សុគុណៈ ទីប៉ោ
២- លោក ហ៊ី រ៉ុង
៣- លោក សំ សាធុច
៤- លោក ឆាយ សុផាន់ណា
៥- លោក ហួយ សោភ័ណ
៦- លោក តែច ផល្លា
៧- លោក ឌិន សារិន
៨- លោក ដុំ ហ៊ិន
៩- លោក អ៊ឹង ស៊ីគេត
១០- លោក គួប ឬទ្ធី

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១២០៦.៦០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១២

លេខ: ៥៦៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
ស៊ុយ សុខា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៨៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការ កែសម្រួលនិងការធ្វើនិយ័តភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបបនីយជីវមណ្ឌលបឹងទន្លេសាប
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានកែសម្រួលអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ទៅជាអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ហៅកាត់ថា "អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក" ។

ជំពូកទី២

រចនាសម្ព័ន្ធ និងការគ្រប់គ្រង

មាត្រា ២.-

អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក មានរចនាសម្ព័ន្ធដូចតទៅ៖

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានបណ្ដាគម្រោង និងកម្មវិធី
- នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
- នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង
- លេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប។

នាយកដ្ឋាននីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។ នាយកដ្ឋាននីមួយៗមានការិយាល័យចំណុះមួយចំនួនតាមការចាំបាច់ ដែលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម តាមសំណើរបស់ប្រធាន គ.ជ.ទ.ម.ក។

ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ។ អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានការិយាល័យត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម តាមសំណើរបស់ប្រធាន គ.ជ.ទ.ម.ក។

រចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់លេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាបត្រូវបានកំណត់ក្នុងអនុក្រឹត្យលេខ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប និងប្រកាសលេខ១៥៤ គ.ជ.ទ.ម.ក-ប្រ.ក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០២ របស់ប្រធាន គ.ជ.ទ.ម.ក ស្ដីពីការរៀបចំនិងការ ប្រព្រឹត្តទៅរបស់អង្គភាពចំណុះលេខាធិការដ្ឋានបបនីយជីវមណ្ឌលបឹងទន្លេសាប។

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ។

មាត្រា ៣.-

អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌមុខងារសាធារណៈ និងអាចមានអ្នកជំនាញការ ឬជាមន្ត្រីជាប់កិច្ចសន្យា ដើម្បីជួយបំពេញការងារតាមការចាំបាច់។

មាត្រា ៤.-

បណ្តាក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ទ.ម.ក ត្រូវបង្កើតអង្គភាពមេគង្គមួយថ្នាក់ស្មើនាយកដ្ឋាន ឬការិយាល័យ ទៅតាមតម្រូវការជាក់ស្តែង ដែលត្រូវរៀបចំ និងស្នើឡើងដោយប្រធានស្ថាប័នសាមីសម្រាប់សម្របសម្រួល និងសហការរាល់សកម្មភាពការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គ។

អង្គភាពមេគង្គមានតួនាទី និងភារកិច្ចដូចតទៅ៖

- ជាផ្នែកបង្គោលនៅក្នុងក្រសួងស្ថាប័ន សម្រាប់រាល់កិច្ចការមេគង្គ
- តាមដានរាល់សកម្មភាពការងារមេគង្គ
- ជួយសម្រួលដល់ដំណើរការទំនាក់ទំនងការងារមេគង្គរវាង គ.ជ.ទ.ម.ក និងក្រសួង-ស្ថាប័នរបស់ខ្លួន
- ចូលរួមកិច្ចប្រជុំការងាររបស់មេគង្គ
- រាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង-ស្ថាប័នរបស់ខ្លួន អំពីសកម្មភាពការងារមេគង្គ
- ជួយការងារដទៃទៀតដែលប្រគល់ជូនដោយក្រសួង-ស្ថាប័នសាមី។

ជំពូកទី៣
តួនាទី និងភារកិច្ច

មាត្រា ៥.-

អគ្គលេខាធិការដ្ឋាន មានតួនាទី និងភារកិច្ចដូចតទៅ៖

- ជាសេនាធិការក្នុងការដឹកនាំ ចាត់ចែង និងសម្របសម្រួលរាល់សកម្មភាពប្រចាំថ្ងៃរបស់ គ.ជ.ទ.ម.ក
- ជាសេនាធិការឲ្យ គ.ជ.ទ.ម.ក ក្នុងកិច្ចសហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ រាជធានី-ខេត្តពាក់ព័ន្ធ បណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ-អន្តរជាតិផ្សេងៗទៀតលើរាល់សកម្មភាពក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
- ធ្វើទំនាក់ទំនង និងសម្របសម្រួលជាមួយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និងគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ លើរាល់សកម្មភាពពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ
- ស្រាវជ្រាវ និងវិភាគទិន្នន័យ ព័ត៌មានពាក់ព័ន្ធនឹងអាងទន្លេមេគង្គកម្ពុជា
- លើកគម្រោង និងកម្មវិធីការងារជាក់ជូនគណៈកម្មការទន្លេមេគង្គ ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិនានា និងប្រភពផ្សេងៗទៀត ដើម្បីរកជំនួយ
- លើកគម្រោងថវិកាសម្រាប់អនុវត្តផែនការសកម្មភាពរបស់ គ.ជ.ទ.ម.ក
- ណែនាំ តាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្តការងាររបស់បណ្តាអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក
- ត្រួតពិនិត្យ តាមដានសកម្មភាពការងាររបស់គណៈកម្មការទន្លេមេគង្គដែលសហការ

ជាមួយក្រសួង-ស្ថាប័នជំនាញ

- បូកសរុបរាល់សកម្មភាព និងសភាពការណ៍ការងារដែលស្ថិតនៅក្នុងក្របខ័ណ្ឌ និងភារកិច្ចរបស់ គ.ជ.ទ.ម.ក
- រាយការណ៍ និងផ្តល់យោបល់ជូនប្រធាន គ.ជ.ទ.ម.ក លើរាល់សកម្មភាពពាក់ព័ន្ធក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនប្រធាន គ.ជ.ទ.ម.ក
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធាន គ.ជ.ទ.ម.ក ប្រគល់ជូន។

មាត្រា៦.-

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ច ដូចតទៅៈ

- ទទួលខុសត្រូវលើកិច្ចការរដ្ឋបាលទូទៅ និងសម្របសម្រួលការងាររដ្ឋបាលជូនគ្រប់អង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក
- ទទួលខុសត្រូវការងារសំណុំលិខិត ឯកសារ លិខិតបទដ្ឋានគតិយុត្តិ ឯកសារសម្ងាត់ ការតម្កល់ឯកសារ ពិធីការ ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ
- រៀបចំគម្រោងផែនការថវិកា សម្ភារៈបរិក្ខារ និងមធ្យោបាយការងារប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក
- ប្រតិបត្តិថវិកាទៅតាមគោលការណ៍លទ្ធកម្ម និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រង និងថែរក្សាអចលនទ្រព្យ ចលនទ្រព្យ
- ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌរបស់ គ.ជ.ទ.ម.ក
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

មាត្រា៧.-

នាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ មានតួនាទី និងភារកិច្ច ដូចតទៅៈ

- រៀបចំផែការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីសម្រេចបាននូវគោលដៅរួមរបស់ គ.ជ.ទ.ម.ក
- ប្រមូលផ្តុំ និងធ្វើសំយោគលទ្ធផលនៃការសិក្សាលើធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គដើម្បីរៀបចំយុទ្ធសាស្ត្រ និងផែនការសម្រាប់ការអភិវឌ្ឍរយៈពេលខ្លី មធ្យម និងវែង
- ស្រាវជ្រាវ ប្រមូលផ្តុំ និងចងក្រងបណ្តាគោលការណ៍ បទដ្ឋានគតិយុត្តិ និងឯកសារបច្ចេកទេសនានាសម្រាប់បម្រើដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាលើការងាររៀបចំផែនការ និងយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី

- ពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
- ជាសេនាធិការឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ធ្វើទំនាក់ទំនង សម្របសម្រួល និងសហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងប្រភពផ្សេងៗទៀត ដើម្បីស្វែងរកជំនួយ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការ ប្រគល់ជូន។

មាត្រា ៨.-

នាយកដ្ឋានបណ្តាគម្រោង និងកម្មវិធី មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សហការ សម្របសម្រួលក្នុងការប្រមូលព័ត៌មាន និងទិន្នន័យពាក់ព័ន្ធធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- សហការ សម្របសម្រួលក្នុងការសិក្សាស្រាវជ្រាវ និងរៀបចំគម្រោង កម្មវិធីគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីសិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់បរិស្ថានក្នុងការប្រើប្រាស់ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- សហការ សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោង និងកម្មវិធីនានាក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី
- វាយការណ៍រាល់សកម្មភាពអនុវត្តការងារគ្រប់គ្រង និងវាយតម្លៃគម្រោង និងកម្មវិធីក្នុងក្របខ័ណ្ឌគណៈកម្មការទន្លេមេគង្គ និងទ្វេភាគី ជូនអគ្គលេខាធិការ
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋាន គតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

មាត្រា ៩.-

នាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ទទួលបន្ទុកការងារគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិក
- រៀបចំក្របខ័ណ្ឌបៀវត្ស គ្រឿងឧបត្ថម្ភ ការលើកទឹកចិត្ត និងការឧបត្ថម្ភផ្សេងៗ
- រៀបចំ និងតម្កល់ឯកសារពាក់ព័ន្ធការងាររបស់មន្ត្រីរាជការ និងបុគ្គលិក
- ពិនិត្យ វាយតម្លៃលើការអនុវត្តការងាររបស់មន្ត្រីរាជការ និងបុគ្គលិក
- សម្របសម្រួលការផ្សព្វផ្សាយដំណឹងជ្រើសរើសមន្ត្រី និងបុគ្គលិក

- រៀបចំផែនការរួមសម្រាប់ការអភិវឌ្ឍធនធានមនុស្ស រយៈពេលខ្លី មធ្យម និងវែង
- រៀបចំគម្រោងថវិកា សម្ភារៈ និងមធ្យោបាយសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស
- សហការ សម្របសម្រួលក្នុងការអនុវត្តនិងគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល ធនធានមនុស្ស
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ជូន។

មាត្រា ១០.-

នាយកដ្ឋានគ្រប់គ្រងព័ត៌មាន និងចំណេះដឹង មានតួនាទី និងភារកិច្ច ដូចតទៅ៖

- ស្រាវជ្រាវ ប្រមូលផ្តុំ ចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យព័ត៌មាននិងចំណេះដឹងពាក់ព័ន្ធបណ្តាគោលការណ៍ បទដ្ឋានគតិយុត្តិនានា និងឯកសារបច្ចេកទេស សម្រាប់បម្រើដល់ការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារ និងរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ ព័ត៌មាន
- រៀបចំបង្កើត និងគ្រប់គ្រងគេហទំព័ររបស់ គ.ជ.ទ.ម.ក
- អភិវឌ្ឍ គ្រប់គ្រង និងកសាងសមត្ថភាពលើការប្រើប្រាស់ឧបករណ៍ បច្ចេកទេស សម្រាប់វិភាគ និងវាយតម្លៃលើគម្រោងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- គ្រប់គ្រង និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសមិទ្ធផល និងសកម្មភាពការងាររបស់ គ.ជ.ទ.ម.ក
- រៀបចំកិច្ចប្រជុំ ធ្វើរបាយការណ៍ កំណត់ហេតុផ្សេងៗ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការ
- អនុវត្តភារកិច្ចផ្សេងទៀតដែលអគ្គលេខាធិការប្រគល់ជូន។

ជំពូកទី៤
អវសានប្បញ្ញត្តិ

មាត្រា ១១.-

អនុក្រឹត្យនេះជំនួសអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដែលត្រូវបាននិរាករណ៍។

មាត្រា ១២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

ប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

លឹម គានហោ

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.....៧៧.....អនក្រ.បក ចុះថ្ងៃទី......ខែ......ឆ្នាំ២០១២
អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤ -អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការឈប់ទទួលស្គាល់សាកលវិទ្យាល័យស៊ីធី

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ បញ្ឈប់ការទទួលស្គាល់សាកលវិទ្យាល័យស៊ីធីដែលមានទីតាំងស្ថិតនៅអគារលេខ ១១៩ ផ្លូវលេខ ២៥៧ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

មាត្រា ២ នាយកសាកលវិទ្យាល័យស៊ីធីត្រូវ ៖

- បញ្ឈប់ធ្វើការបណ្តុះបណ្តាលគ្រប់កម្រិតសិក្សា និងគ្រប់រូបភាព
- ដោះស្រាយរាល់បញ្ហានានាដែលនៅសេសសល់ជាមួយនិស្សិត និងភាគីពាក់ព័ន្ធក្នុងដំណើរការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យនាពេលកន្លងមកឲ្យបានចប់សព្វគ្រប់។

មាត្រា ៣ អនុក្រឹត្យលេខ ៩៩ អនក្រ.បកចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០៥ ស្តីពីការទទួលស្គាល់សាកលវិទ្យាល័យស៊ីធី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យស៊ីធីត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ មិថុនា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៩ - អនក្រ - បក

អនុក្រឹត្យ
ស្តីពី
ការប្រើប្រាស់គណនី
ឯកជនភាពូបនីយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនុក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនការរូបនីយកម្មសហគ្រាសសាធារណៈ ចំនួន ៣៧០ ៣១១,៧២ ដុល្លារអាមេរិក (បីរយចិតសិបពាន់បីរយដប់មួយដុល្លារអាមេរិក និងចិតសិបពីរសេន) ក្នុងនោះ ចំនួន ៣៦១ ៨៩៨ ដុល្លារអាមេរិក សម្រាប់ចំណាយលើថ្លៃទិញឈើសាងសង់អគារទីស្តីការនាយករដ្ឋមន្ត្រីនិងមជ្ឈមណ្ឌលសន្និសីទអន្តរជាតិនិងចំនួន ៨ ៤១៣,៧២ ដុល្លារអាមេរិក សម្រាប់ចំណាយលើការងារសាងសង់របង និងដំឡើងទ្វារដែកសុវត្ថិភាពផ្នែកខាងក្រោយអគារទីស្តីការនាយករដ្ឋមន្ត្រី និងថ្លៃផ្គត់ផ្គង់ម៉ូទ័រ គ្រឿងបន្លាស់ម៉ាស៊ីនយោងសំអាតបង្គួច-ជញ្ជាំង នៅអគារទីស្តីការនាយករដ្ឋមន្ត្រី និងមជ្ឈមណ្ឌលសន្និសីទអន្តរជាតិ (វិមានសន្តិភាព) ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា (ដើម្បីជូនជ្រាប)
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦០. អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃមន្ទីរទេសចរណ៍រាជធានី ខេត្តនៃក្រសួងទេចរណ៍ ចំនួន១០៦រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ លើវិស័យទេសចរណ៍ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១	លោក ម៉ក់ ស៊ីនណារ៉ា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
២	លោក ឈឿន សេរីវុធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៣	លោក ប៊ិន គឹមលាត	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ
៤	លោក រស់ សុខ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
៥	លោក វន ទុំ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង
៦	លោក ឯម សុវណ្ណារ៉ា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
៧	កញ្ញា ស៊ិន សុខនឿន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ

៨	លោកស្រី អ៊ឹម ចន្ថា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៩	លោកស្រី ថ្មម សុខឃីម	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តក្រចេះ
១០	លោក ផាន់ ណារ៉ាត	ប្រធានការិយាល័យខណ្ឌដូនពេញ មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១១	លោកស្រី ភួង បុប្ផាភានី	ប្រធានការិយាល័យខណ្ឌ៧មករា នៃមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១២	លោក ប្រាក់ ឡុង	ប្រធានការិយាល័យខណ្ឌចំការមន មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១៣	លោក តុង រិត	ប្រធានការិយាល័យខណ្ឌទួលគោកនៃមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១៤	លោក ឃុន សាន	ប្រធានការិយាល័យខណ្ឌឫស្សីកែវ នៃមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១៥	លោក លឹម បែន	ប្រធានការិយាល័យខណ្ឌមានជ័យ នៃមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១៦	លោកស្រី សន សំអឿន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
១៧	លោក អ៊ុន ប៊ុនថុន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង
១៨	លោក នួន ថា	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
១៩	លោក កង លីចណ្ណារ៉េន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
២០	លោក តូវ ជីហ្វុង	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
២១	លោក អឿន វិបុល	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
២២	លោក ទេព រិន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
២៣	លោក ផុក ស៊ីផាង	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ

ខ-មេដាយ ប្រាក់ ការងារ

១	លោកស្រី លួន ធានី	ប្រធានមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង
២	លោក អ៊ុច អ៊ុំភីនីស្សារ៉ា	ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៣	លោក ឌី ស៊ីថុន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៤	លោកស្រី ជា សុបាន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៥	លោក ម៉ៅ នីរុ	អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
៦	លោក អឿន រិទ្ធ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម
៧	លោក ពុធ សុរិយា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
៨	លោក ស៊ន សារុន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
៩	លោក សៅ សារ៉ន	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១០	លោកស្រី ម៉ាង ម៉ាយុដា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង
១១	លោក ឃីម សានិត	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង
១២	លោក លីវត្ថាវ៉ាន់	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកោះកុង
១៣	លោក កង តន្ទ្រី	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
១៤	លោកស្រី ហ៊ិន ដានី	អនុប្រធានមន្ទីរទេសចរណ៍ខេត្តតាកែវ
១៥	លោក សូ ផាន្នី	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពត

១៦	លោក ប្រាជ្ញ ឌីណា	អនុប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ
១៧	លោក សៅ សម	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តតាកែវ
១៨	លោក ឈូក ប៊ុនថន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តតាកែវ
១៩	លោក គាំ កាណន់	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តតាកែវ
២០	លោកស្រី ម៉ី សារឹម	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
២១	អ្នកស្រី ប៉ុល រ័ក្សដែន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តមណ្ឌលគិរី
២២	លោកស្រី អ៊ឹង ដារី	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
២៣	លោក ទុយ វ៉ុង	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
២៤	លោកស្រី ឈុំ អួន	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបាត់ដំបង
២៥	លោកស្រី ស៊ុំ សុគន្ធា	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តរតនគិរី
២៦	លោក សុខ ចាន់គ្រិះស្នា	ប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកោះកុង
២៧	លោក វ៉ា ឈៀង	ប្រធានការិយាល័យ អភិវឌ្ឍន៍វប្បធម៌មន្ទីរទេសចរណ៍ខេត្តកោះកុង
២៨	លោកស្រី ប៊ុន សំបូរណ៍	ប្រធានការិយាល័យឧស្សាហកម្មមន្ទីរទេសចរណ៍ខេត្តកោះកុង
២៩	លោកស្រី ទូច សារឿន	ប្រធានការិយាល័យព័ត៌មាន មន្ទីរទេសចរណ៍ខេត្តកោះកុង
៣០	លោក អ៊ុង ស៊ីយឿន	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តក្រចេះ
៣១	លោក ង៉ាន គឹមលី	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៣២	លោក ប៉ុក ធឿន	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
៣៣	លោក ចាន់ សាម៉េត	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
៣៤	លោក ព្រំ សំអាត	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
៣៥	លោក គង់ ឧត្តមជ័យរិទ្ធ	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តស្វាយរៀង
៣៦	លោក សុំ សារ៉ន	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
៣៧	លោកស្រី ឡុង បូណារ៉េត	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
៣៨	លោកស្រី ប្រាំង សុចារី	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពង់ចាម
៣៩	លោក គិន បូកាន	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកោះកុង
៤០	លោកស្រី អ៊ិន សុម៉ាឡា	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកោះកុង
៤១	លោក ប៊ុន ថេង	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តក្រចេះ
៤២	លោកស្រី ញ៉ិប ភារី	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តក្រចេះ
៤៣	លោក ចាប រិន	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៤៤	លោកស្រី ស្រី វ៉ះ	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៤៥	លោកស្រី យឹម ម៉ាលី	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៤៦	លោកស្រី ចឹក សុភ័ក្ត្រ	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៤៧	លោកស្រី អាន សុខឿន	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង

៤៨	លោក យី យីម	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តកោះកុង
៤៩	លោក ប៉ុល ស៊ីមហេង	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះវិហារ
៥០	លោក ឈឹម ដឿន	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥១	លោក គឹម សម្បត្តិ	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥២	លោក វាសនា ឆាយា	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥៣	លោកស្រី ប៉ាត សុថាល័យ	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥៤	លោក ប៊ូ វិបុល	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥៥	លោក ហង្ស សាម៉ែ	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តកំពត
៥៦	លោក ហុក ឃួន	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៥៧	លោក លន់ផល	អនុប្រធានការិយាល័យ មន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៥៨	លោក កាត់ កូនណុប	មន្ត្រី មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
៥៩	លោក ឃុំ យ៉ាតយ៉ាន់	មន្ត្រី មន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ

គ-មេដាយ សំរិទ្ធ ការងារ

១	លោកស្រី កែវ រ័ត្នតារា	អនុប្រធានមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
២	លោក ខឿន សុវណ្ណ	អនុប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
៣	លោក យឹម ចិន្តា	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តកំពត
៤	កញ្ញា គឹម លាងវួច	ប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៥	លោក ឆេង ផារី	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៦	លោក ម៉ៃ និមល	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៧	លោកស្រី រាជ ហ៊ល	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តព្រះសីហនុ
៨	លោក ម៉ុក សេកាណូ	អនុការិយាល័យមន្ទីរទេសចរណ៍ខេត្តកំពត
៩	លោក ម៉ៅ សុវឌ្ឍន៍	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍រាជធានីភ្នំពេញ
១០	លោកស្រី ចំ សុខណារិន	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តកែប
១១	លោក គឹម សម្បត្តិ	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១២	លោក វាសនា ឆាយ៉ា	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ
១៣	លោក រេត រឿម	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
១៤	លោក ធុល អ៊ាង	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
១៥	លោក ព្រឿង ឡុង	អនុប្រធានការិយាល័យមន្ទីរទេសចរណ៍ខេត្តបាត់ដំបង
១៦	លោក ហ៊ុន ពិសី	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៧	កញ្ញា ប៊ុ បុប្ផា	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៨	លោក ឌុច ប៊ុនលី	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
១៩	កញ្ញា ឈៀវ ឆារី	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
២០	កញ្ញា បាន សុធីតា	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ

២១	កញ្ញា ថាន សោភា	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពង់ស្ពឺ
២២	លោក ប៉ុន សំបូរ	មន្ត្រី មន្ទីរទេសចរណ៍ខេត្តក្រចេះ
២៣	លោកស្រី ទិត សុផល	អនុការិយាល័យមន្ទីរទេសចរណ៍ខេត្តកំពត
២៤	លោក តេង វុទ្ធី	មន្ត្រី មន្ទីរទេសចរណ៍ខេត្តកំពត

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦១ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៃក្រសួងទេសចរណ៍ ចំនួន៦២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ លើវិស័យទេសចរណ៍ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ

១	ឯកឧត្តម ណេប សាមុត	អគ្គនាយករងទេសចរណ៍ និងជាអគ្គលេខាធិការ នៃគ.ជ.វ.ទ
២	ឯកឧត្តម សុខ សង្វារ	អគ្គលេខាធិការរង នៃគ.ជ.វ.ទ
៣	ឯកឧត្តម វ៉ាត់ ចំរើន	នាយករងខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
៤	លោក ផ្លុង ធឿន	អគ្គនាយករងទេសចរណ៍
៥	លោក ចុក សុខុម	ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
៦	លោក សុខ សុគុណ	ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍទេសចរណ៍
៧	លោក វ៉ែន ធីម	ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង
៨	លោក ឥន្ទ អ៊ិនសារី	ទីប្រឹក្សាក្រសួងទេសចណ៍
៩	លោក កែវ ភួង	ទីប្រឹក្សាក្រសួងទេសចណ៍

១០	លោក ហេង សុខចំរើន	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល និងជាទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី ឋានៈស្មើប្រធាននាយកដ្ឋាន
១១	លោក គោស៊ុំ ប៊ុនសឿត	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
១២	លោក ហ៊ុយ ភីរក្ស	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១៣	លោក ឡោ សុវិជ្ជា	អធិការរង នៃអធិការដ្ឋានក្រសួងទេសចរណ៍
១៤	លោក សៅរ៍ ចាន់ណា	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៥	លោក ចិន សាម៉ន	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៦	លោក នូ សុផល	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៧	លោក ម៉ម វាសនា	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
១៨	លោក ពៅ វ៉ារ៉ូ	អនុប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស
១៩	លោក សោម ប៊ុនណាត	នាយការិយាល័យ នា.សហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
២០	លោក ចៅ វណ្ណរិទ្ធ	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ

ខ-មេដាយសុវត្ថារា ថ្នាក់សេនា

១	លោក ហេង សុជានី	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
២	លោក ឈឹម សុខជិន	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
៣	លោកស្រី ផ្កា ស៊ីណា	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
៤	លោកស្រី ចាយ សុវណ្ណនី	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
៥	លោក នាង វិបុល	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
៦	លោក ទូន សេដា	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៧	លោកស្រី ឯម វ៉ាន់សារ៉ារ័ត្ន	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
៨	លោក យិន ស៊ីផេង	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
៩	លោក ឆឹង មុន្នី	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
១០	លោក នឹម សុវណ្ណ	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
១១	លោក វ៉ែន មុនីវឌ្ឍនៈ	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
១២	លោក សយ ផល្លា	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១៣	លោក ឈុន ណាក់	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១៤	លោកស្រី ប៉ូច វរលក្ខណ៍	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
១៥	លោក ស៊ិន សុកគេន	ជំនួយការរដ្ឋមន្ត្រី
១៦	លោក ណែម ស៊ីវឌ្ឍនា	នាយការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
១៧	លោក ប៉ែន សុវណ្ណា	នាយការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
១៨	លោក ទិត្យ វ៉េត	នាយការិយាល័យ នា.អប់រំបណ្តុះបណ្តាល

១៩	លោក ហង់ រស្មី	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២០	លោក កែវ សំណាង	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២១	លោក នូ ណូរ៉ា	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២២	លោក សៀង នាគ	នាយការិយាល័យ នា.សហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន
២៣	លោក ប្រាក់ណារ៉ាន់	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
២៤	លោក ស្រេន សុវណ្ណារ៉ា	នាយការិយាល័យ នា.ទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន
២៥	លោកស្រី ហ៊ីង ច័ន្ទបុប្ផា	នាយការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
២៦	លោក ឡុង សិលារ័ត្ន	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
២៧	លោក ឡេង ពីឡុត	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
២៨	កញ្ញា ហង្ស សៅវ៉ាន់ឌី	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
២៩	កញ្ញា អន ស៊ីនី	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
៣០	លោក ម៉ៅ ហួន	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
៣១	លោកស្រី ព្រំ សុភារិន	នាយរងការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
៣២	លោកស្រី គុណ ពុធីតា	នាយរងការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
៣៣	លោកស្រី ឈន សុខទាង	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៤	កញ្ញា យ៉ាន់ វ៉ារី	នាយរងការិយាល័យ នា.គណនេយ្យ និងហិរញ្ញវត្ថុ

គ-មេដាយ សុវត្ថារា ថ្នាក់អស្សឫទ្ធិ

១	លោកស្រី តឹក សុភី	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
២	លោក ហង្ស សណ្តាប់	អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
៣	លោក អៀ វុត្ថារ៉ា	នាយការិយាល័យ នា.គណនេយ្យ និងហិរញ្ញវត្ថុ
៤	កញ្ញា ត្រួយ លីនដា	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
៥	លោក ម៉ម ម៉ានីរដ្ឋ	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
៦	លោក ហ៊ិត វណ្ណនី	នាយការិយាល័យ នា.ស្ថិតិ និងព័ត៌មានទេសចរណ៍
៧	លោកស្រី ម៉ិល សុខចាន់	នាយរងការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
៨	លោកស្រី លុក ដូនី	នាយរងការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៦៧ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការប្រគល់មេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងទេសចរណ៍ ចំនួន២០៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិ លើវិស័យទេសចរណ៍ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ មាស ការងារ

១	លោក ជា កុសល	ប្រធានក្រុមអ្នកច្បាប់
២	លោក ហុក លឹម	ទីប្រឹក្សាក្រសួងទេសចរណ៍
៣	លោក ហ៊ឹម សុភា	ទីប្រឹក្សាក្រសួងទេសចរណ៍
៤	លោកស្រី កុប អែសៈ	ជំនួយការរដ្ឋមន្ត្រី
៥	លោក ហុង សៀង	អនុប្រធានក្រុមអ្នកច្បាប់
៦	លោក ស៊ូ គឹមព្រឹទ្ធា	អនុប្រធានក្រុមអ្នកច្បាប់
៧	លោក ប៉ែន ចាន់ថា	អធិការង នៃអធិការដ្ឋានក្រសួងទេសចរណ៍
៨	លោក នៅ គីឡា	អធិការង នៃអធិការដ្ឋានក្រសួងទេសចរណ៍
៩	លោក ធីម ថារិទ្ធ	អធិការង នៃអធិការដ្ឋានក្រសួងទេសចរណ៍
១០	លោក នុត នារក្ស	អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍
១១	លោកស្រី ហួត ស៊ីនួន	អនុប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍
១២	លោក ឡោ ធូរ៉ា	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ

១៣	លោក ហ៊ុល សីលា	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ
១៤	លោកស្រី ប៊ុន ខេមា	អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល
១៥	លោក ប៊ូ ច័ន្ទសិរី	អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍទេសចរណ៍
១៦	លោក ជួប សោភ័ណ	អនុប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន
១៧	លោក ពត ជាវលី	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៨	លោក លីវ វណ្ណហេង	អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍
១៩	លោក តាត វិសុទ្ធមុនី	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
២០	លោក ខួង បញ្ញាវុធ	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
២១	លោក សុខ សំអាត	នាយការិយាល័យ នា.សិក្សាទីផ្សារ និងផ្សព្វផ្សាយ
២២	លោក ម៉ុក ម៉ារី	នាយការិយាល័យ នា.អប់រំបណ្តុះបណ្តាល
២៣	លោក ពុទ្រា សោភ័ណ្ឌារ៉ា	នាយការិយាល័យ នា.អប់រំបណ្តុះបណ្តាល
២៤	កញ្ញា លន ណារី	នាយការិយាល័យ នា.អប់រំបណ្តុះបណ្តាល
២៥	កញ្ញា ហួតនន់ សុខាវណ្ណាណែត	នាយការិយាល័យ នា.អប់រំបណ្តុះបណ្តាល
២៦	លោកស្រី ដោក ស៊ីណារ៉ា	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២៧	លោក សូ ខីណា	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២៨	កញ្ញា អ៊ីវ និមល	នាយការិយាល័យ នា.ឧស្សាហកម្មទេសចរណ៍
២៩	លោក មុយ សែ	នាយការិយាល័យ នា.គណនេយ្យ និងហិរញ្ញវត្ថុ
៣០	លោក អ៊ឹង ឈុនលី	នាយការិយាល័យ នា.គណនេយ្យ និងហិរញ្ញវត្ថុ
៣១	លោក លឹក គឹមយឿន	នាយការិយាល័យ នា.គណនេយ្យ និងហិរញ្ញវត្ថុ
៣២	លោក ស៊ឹម ចន្ថា	នាយការិយាល័យ នា.បុគ្គលិក និងអ.ភិធនធានមនុស្ស
៣៣	លោក នុត សុខា	នាយការិយាល័យ នា.ផែនការអភិវឌ្ឍ
៣៤	លោកស្រី ទឹម ស៊ីម៉ុន	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៥	លោកស្រី សារិន កញ្ញានា	នាយការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៦	លោកស្រី លាង សុផល	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៧	លោកស្រី វ៉ាត សារាំង	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៨	លោក ចែ សុវណ្ណារ៉េត	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
៣៩	លោកស្រី ម៉ែន ម៉ូរ៉ាដានី	នាយរងការិយាល័យ នា.រដ្ឋបាល និងកិច្ចការទូទៅ
